ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន
# កម្ពុជា និងក្រិក ពិភាក្សាអំពីការលើកកម្ពស់ទំនាក់ទំនង

ឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងឯកឧត្តម **Nikos Dendias** រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋក្រិក បានពិភាក្សាអំពីមធ្យោបាយដើម្បីពង្រឹងបន្ថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ក្នុងអំឡុងពេលជំនួបទ្វេភាគី នៅថ្ងៃទី ០២ ខែសីហា ឆ្នាំ២០២២ នៅក្នុងឱកាសនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ និងកិច្ចប្រជុំពាក់ព័ន្ធក្នុងក្របខ័ណ្ឌអាស៊ាន រៀបចំដោយកម្ពុជា។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន និងឯកឧត្តមរដ្ឋមន្ត្រីការបរទេស Nikos Dendias បានរំលឹកឡើងវិញដោយក្តីពេញចិត្តចំពោះការបង្កើតយន្តការពិគ្រោះយោបល់ទ្វេភាគី តាមរយៈការចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នា នៅពីថ្ងៃទី ៨ ខែកក្កដា ឆ្នាំ២០២១ និងកិច្ចប្រជុំពិគ្រោះយោបល់ទ្វេភាគីលើកទី១ប្រកបដោយផ្លែផ្ការវាងក្រសួងការបរទេសនៃប្រទេសទាំងពីរ នៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០២២ នៅទីក្រុងអាថែន។ រដ្ឋមន្ត្រីការបរទេសទាំងពីរបានឯកភាពបន្តកិច្ចពិគ្រោះយោបល់ទ្វេភាគីឱ្យទៀងទាត់ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការបន្ថែមទៀត។ ឯកឧត្តមរដ្ឋមន្ត្រីការបរទេសទាំងពីរ បានឯកភាពបង្កើតការផ្សារភ្ជាប់ទំនាក់ទំនងរវាងធុរកិច្ចនិងធុរកិច្ច សំដៅពង្រឹងទំនាក់ទំនងសេដ្ឋកិច្ច និងស្វែងរកលទ្ធភាពសម្រាប់ការជំរុញកិច្ចសហប្រតិបត្តិការទេសចរណ៍រវាងប្រទេសទាំងពីរ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន បានអបអរសាទរប្រទេសក្រិកចំពោះការចូលជាសមាជិកនៃសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (TAC) និងបានគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងនាមជាប្រធានអាស៊ាននៅឆ្នាំនេះ ក្នុងការធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រិក ដើម្បីពង្រឹងទំនាក់ទំនងកាន់តែជិតស្និទ្ធរវាងអាស៊ាន-ក្រិក និងអាស៊ាន-សហភាពអឺរ៉ុប។ ឯកឧត្តមរដ្ឋមន្ត្រីការបរទេស Nikos Dendias បានថ្លែងអំណរគុណចំពោះការគាំទ្ររបស់កម្ពុជាក្នុងគោលបំណងនេះ និងបានអបអរសាទរកម្ពុជាចំពោះភាពជោគជ័យនៃការធ្វើជាប្រធានអាស៊ាន។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន និងឯកឧត្តមរដ្ឋមន្ត្រីការបរទេស Nikos Dendias ក៏បាន

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

ពិភាក្សាផងដែរអំពីកិច្ចសហប្រតិបត្តិការលើឆាកអន្តរជាតិ ដែលក្នុងឱកាសនោះ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានអះអាងចំពោះសមភាគីរបស់ ឯកឧត្តម អំពីការពិចារណាយ៉ាងយកចិត្តទុកដាក់ចំពោះសំណើរបស់ប្រទេសក្រិក សុំឱ្យកម្ពុជាគាំទ្របេក្ខភាពរបស់ក្រិកនៅក្នុងអង្គការអន្តរជាតិមួយចំនួន៕

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែសីហា ឆ្នាំ២០២២

អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**ជុំ សុន្ទរី**